**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ: ១៨៤ គ.ក.ល

ថ្ងៃ អង្គារ ១២ កើត ខែ មិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០២៥

**សូមជម្រាបជូន**
**លោកប្រធានក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**

**កម្មវត្ថុ**: ប្រកាសលុបចោលការដេញថ្លៃស្តីពីការផ្តល់សេវាចងក្រងសៀវភៅក្បួនសវនកម្មផ្ទៃក្នុង (Internal Audit Manual) ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ផែនការកែតម្រូវ-ឆ្នាំ២០២៥)។
**យោង**: កំណត់ហេតុបើកឯកសារដេញថ្លៃ(លើកទី២) ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានក្រុមហ៊ុនមេត្តាជ្រាបថា៖ យោងតាមការវាយតម្លៃលើឯកសារដេញថ្លៃរបស់ក្រុមហ៊ុនស្តីពីការផ្តល់សេវាចងក្រងសៀវភៅក្បួនសវនកម្មផ្ទៃក្នុង (Internal Audit Manual) ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ឃើញថា លក្ខខណ្ឌការងារមិនសមស្របហ្នឹងតម្រូវការ ហើយតម្លៃដែលបានដាក់ដោយក្រុមហ៊ុនខ្ពស់ជាងឥណទានជានាចំណាយទ្វេដង ដូចនេះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមប្រកាសលុបចោលការដេញថ្លៃនេះ។

ក្រុមហ៊ុនអាចដាក់ពាក្យដកប្រាក់កក់ធានាការដេញថ្លៃពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃប្រកាសនេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកក្រុមហ៊ុនមេត្តាជ្រាប និងអធ្យាស្រ័យ។

សូម លោកប្រធានក្រុមហ៊ុន ទទួលនូវការគោរពរាប់អានពីខ្ញុំ។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធាន**

**ជូ ផល្លា**

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-គ្រប់សមាជិកគណៈកម្មាធិការលទ្ធកម្ម
-អង្គភាពលទ្ធកម្ម
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ

អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ៣១ ៩៣៥ ៨០ ៨០ Email: admin@ppwsa.com.kh